**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តក្រចេះ**

**សំណុំរឿងរដ្ឋប្បវេណីលេខ ១៥២**

**ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០១៩**

**សាលក្រមលេខ ១១៨ "ច"**

**ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០២០**

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តក្រចេះ**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ នាសាលសវនាការនៃសាលាដំបូងខេត្តក្រចេះ ។

**សមាសភាពនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់មានដូចតទៅ៖**

លោកស្រី [redacted] ជាចៅក្រម នៃសាលាដំបូងខេត្តក្រចេះ

លោកស្រី [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តក្រចេះ

**គូភាគី៖**

**រវាងដើមចោទ៖** ឈ្មោះ [redacted] **ស៊ីណាត** ភេទស្រី អាយុ៥៤ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted]។ មេធាវីតំណាងដោយអាណត្តិឈ្មោះ [redacted]។

**និងចុងចម្លើយ៖** ឈ្មោះ [redacted] **សេងហ៊ាង** ភេទប្រុស អាយុ៥៧ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted]។ មេធាវីតំណាងដោយអាណត្តិឈ្មោះ [redacted]។

**១.អង្គហេតុ និងចំណុចវិវាទ**

**១.១. ខ្លឹមសារនៃសាលក្រមដែលតវ៉ាតទាមទារ៖**

**ក. ខ្លឹមសារនៃសាលក្រម ដែលដើមចោទនៃបណ្តឹងដើមទាមទារឲ្យតុលាការចេញ៖**

-ប្តឹងសុំលែងលះជាមួយប្តីឈ្មោះ [redacted] សេងហ៊ាង តាមផ្លូវច្បាប់

-កំណត់យកឈ្មោះ [redacted] ស៊ីណាត ជាអ្នកមានអំណាចមេបាលើកូនប្រុសពីរនាក់៖ ១.ឈ្មោះ [redacted] សេងហួរ ភេទប្រុស កើតថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៤ និង២.ឈ្មោះ [redacted] សេងហុង ភេទប្រុស កើតថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦។

-ប្តឹងទាមទារសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រង និងថែរក្សាកូនចំនួន១៥០ដុល្លារអាមេរិកសម្រាប់កូនម្នាក់ៗក្នុងមួយខែ។

-បង្គាប់ឲ្យចុងចម្លើយប្រគល់ដី និងផ្ទះលំនៅឋានដែលជាទ្រព្យសម្បត្តិកេរ្តិ៍ដំណែលជូនតា មានទីតាំងស្ថិតនៅភូមិអូរឫស្សីទី១ សង្កាត់អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់



Scanned with CamScanner

-គ្រែឈើធំ(គ្រែយក្ស)ចំនួន១

-សាឡុងឈើចំនួន១ឈុត

-ទូឈើចំនួន៥គ្រឿង

-តុឈើមូលចំនួន២ឈុត

-កៅអីឈើចំនួន១២

-តុឈើបត់ចំនួន២

-តុការិយាល័យឈើចំនួន២

-ទូសំអាងឈើ១

-គ្រែឈើជើងគ្រុតចំនួន២

-សុំទទួលខុសត្រូវបំណុលរួមដែលជំពាក់ធនាគារអាស៊ីវឌ្ឍនៈចំកាត់ABA BANK ចំនួន ៨៥,៧១៤ (ប្រាំបីម៉ឺនប្រាំពាន់ប្រាំពីររយដប់បួន) ដុល្លារអាមេរិក និងការប្រាក់រហូតដល់សងបំណុលរួច។

-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយនៃបណ្ដឹងតប។

**១.២. អង្គហេតុ៖**

**ក. ការសង្ខេបអង្គហេតុ**

ក្នុងរឿងនេះ ដើមចោទបានអះអាងថា ដើមចោទ និង ចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍ជាប្ដីប្រពន្ធនឹងគ្នា ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ១៧ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ត្រឹមត្រូវតាមច្បាប់។ ក្នុងការរស់នៅជាមួយគ្នា តែងតែឈ្លោះទាស់ទែងប្រកែក មិនចុះសម្រុងគ្នា ដែលជាហេតុនាំឱ្យមានការសុំលែងលះ។ ក្នុងចំណងអាពាហ៍ពិពាហ៍ មានកូនចំនួន០២នាក់ កូនទី១ ឈ្មោះ [redacted] សេងហួរ ភេទប្រុស កើតថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៤ និងទី២ឈ្មោះ [redacted] សេងហុង ភេទប្រុស កើតថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦។ ដើមចោទសុំសិទ្ធិជាអ្នកមានអំណាចមេបាលើកូនទាំងពីរ និងសោហ៊ុយចាំបាច់ ដើម្បីគ្រប់គ្រង និងថែរក្សាកូន ១៥០ (មួយរយហាសិប) ដុល្លារអាមេរិក ក្នុងមួយខែសម្រាប់កូនម្នាក់ៗ និងទាមទារបែងចែកទ្រព្យសម្បត្តិរួមធ្វើជាការចាត់ចែងបន្ទាប់បន្សំផងដែរ។

**ខ. អង្គហេតុដែលគ្មានវិវាទ**

ដើមចោទ និងចុងចម្លើយ ពីការរស់នៅជាមួយគ្នាមិនចុះសម្រុង និងមិនអាចធ្វើបដិទាននូវទំនាក់ ទំនងអាពាហ៍ពិពាហ៍នោះបាន។ ចំណែកទ្រព្យសម្បត្តិរួមមួយចំនួនដែលភាគីទាំងពីរទទួលស្គាល់ និងឯកភាពគ្នាបែងចែកជាពីរចំណែកស្មើគ្នាតាមផ្លូវច្បាប់មានដូចជា ដីទំហំ២១១ម៉ែត្រការ៉េ ស្ថិតនៅភូមិអូរឬស្សីទី១ សង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១០០២១០០៣-០៤៤១ ចុះថ្ងៃ ទី១៥ ខែធ្នូ ឆ្នាំ២០១៤ និងដីទំហំ៦៨៧ម៉ែត្រការ៉េ ស្ថិតនៅភូមិអូរឬស្សីទី២ សង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១០០២១០០៤-០៩៦៨ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧។

**១.៣. ចំណុចដែលមានវិវាទ៖**

តើដើមចោទ ឬចុងចម្លើយជាអ្នកផ្ដល់ឧត្តមប្រយោជន៍បំផុតដល់កូន?



Scanned with CamScanner

គុណនឹង៥០ម៉ែត្រ មានផ្ទះចាស់ ហើយបានរុះរើសង់ថ្មីជាមួយចុងចម្លើយ។ ចំណែកដីខាងក្រោយជាប់គ្នាគឺបងប្រុសរបស់ខ្លួនបានទិញ និងឱ្យមកខ្លួន។ នៅពេលមានការចុះបញ្ជីកម្មសិទ្ធិខ្លួនបានសម្រេចចិត្តយកចុះបញ្ជីទ្រព្យរួមដោយហេតុថា ខ្លួនរស់នៅជាប្ដី ស្មោះត្រង់ជាមួយប្ដី មិនអាចបែកគ្នា និងងាយស្រួលក្នុងការខ្ចីប្រាក់ពីធនាគារ។ ចំពោះការសាងសង់ផ្ទះលើដីនោះ និងតម្លៃនៃផ្ទះនោះ ខ្លួនមិនដឹងនោះទេ។

ចំពោះគ្រឿងសង្ហារិមដែលចុងចម្លើយទាមទារថាមាននៅក្នុងផ្ទះនោះ គឺមិនមាននោះទេ ចុងចម្លើយបានដឹកជញ្ជូនទៅអស់ហើយ។

**ខ.២. ការអះអាងរបស់ចុងចម្លើយ**

ចំពោះដីចំការទំហំ១០០០០(មួយម៉ឺន)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិចង្រ្កង ឃុំកសាង ស្រុកចិត្របុរី ខេត្តក្រចេះ ដែលដើមចោទលើកឡើង គឺមិនមាននោះទេ ខ្លួនមិនបានទិញឡើយមិត្តភ័ក្តរបស់ខ្លួនបានឱ្យមកខ្លួន តែមិនមានឯកសារណាមួយបញ្ជាក់នោះទេ ព្រោះដីនោះជាប្រភេទដីព្រៃ។ ខ្លួនមិនដែលធ្លាប់ទៅមើលដីដែលគេឱ្យនោះទេ ហើយក៏មិនដឹងស្ថិតនៅកន្លែងណានោះដែរ។

ចំពោះដី និងផ្ទះ ទំហំ៦៨០ម៉ែត្រការ៉េ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១០០២១០០៣-០៤២៤ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ ខ្លួន និងដើមចោទបានទិញដីខាងក្រោយពង្រីកបន្ថែមកាលពីអំឡុងឆ្នាំពីរពាន់ជាង ដោយឱ្យបងប្រុសរបស់ដើមចោទជាអ្នកទិញដោយសារតែខ្លួនមិនត្រូវគ្នាជាមួយម្ចាស់ដីដោយប្រាក់ខ្លួនជាឱ្យទៅទិញក្នុងតម្លៃ៣៥០$ តែមិនមានឯកសារនោះទេ។ ការដែលដើមចោទដាក់ដីដែលជាកេរ្តិ៍របស់ម្ដាយជាទ្រព្យសម្បត្តិរួម ខ្លួនមិនបានបង្ខិតបង្ខំនោះទេ កើតចេញពីការព្រមព្រៀងគ្នា។ ចំណែកឯផ្ទះដែលសាងសង់លើដីនោះចំណាយអស់ប្រហែល៦០០០០$ ដែលជាប្រភេទផ្ទះឈើ និងក្រោមរៀបជញ្ជាំងឥដ្ឋ និងមានបំពាក់គ្រឿងសង្ហារិមជាច្រើនក្នុងផ្ទះផងដែរ។

ចំពោះគ្រឿងសង្ហារិមមានដូចជា ទូទឹកកកចំនួន២គ្រឿង ទូក្លាសេចំនួន២គ្រឿង គ្រែផ្តុំធ្វើអំពីឈើចំនួន៤ គ្រែឈើធំ(គ្រែយក្ស)ចំនួន១ សាឡុងឈើចំនួន១ឈុត ទូឈើចំនួន៥គ្រឿង តុឈើមូលចំនួន២ឈុត កៅអីឈើចំនួន១២ តុឈើបត់ចំនួន២ តុការិយាល័យឈើចំនួន២ ទូសំអាងឈើ១ គ្រែឈើជើងគ្រុតចំនួន២ មាននៅក្នុងផ្ទះខ្លះ និងក្រោមផ្ទះខ្លះ តែខ្លួនមិនមានអ្វីមកបញ្ជាក់នោះទេ។

**២. សំអាងហេតុ**

**ឆ្លងកាត់តាមនិតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់**

**និង ក្រោយពីពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

**យល់ឃើញថា៖**

**ក. ការវិនិច្ឆ័យចំពោះលែងលះ**

**ក.១. ការទទួលស្គាល់អង្គហេតុ**

ដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមច្បាប់ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ១៧ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤។ ដើមចោទ និងចុងចម្លើយ មិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ទេ



Scanned with CamScanner

គ.១.១. បច្ចុប្បន្ននេះ ដើមចោទគ្មានប្រាក់ចំណូលទៀតទាត់នោះទេ តែដើមចោទកំពុងតែគ្រប់គ្រង និងថែរក្សាកូនទាំងពីរ ដោយពួកគេទាំងពីរកំពុងតែនៅសិក្សា។

គ.១.២. ចុងចម្លើយជាមន្ត្រីយោធាចូលនិវត្តន៍ និងមានមុខរបរបើកសិប្បកម្មឈើ ដែលមានចំណូលទៀងទាត់។

គ.១.៣ ចុងចម្លើយបច្ចុប្បន្នជួលផ្ទះគេ និងមានលទ្ធភាពបង់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រង និងថែរក្សាកូនចន្លោះពី៥០ម៉ឺន ទៅ៦០ម៉ឺនរៀលក្នុងមួយខែ។

**គ.២. សេចក្តីសន្និដ្ឋាន**

ផ្អែកតាមការសរុបអង្គហេតុដែលបានទទួលស្គាល់នៅក្នុងចំណុចក.១.ខាងលើ តុលាការទទួលស្គាល់ថាសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រង និងថែរក្សាកូនទាំងពីរ ដែលចុងចម្លើយមានលទ្ធភាពអាចបង់បាន គឺមានតែ៦០ម៉ឺនរៀលក្នុងខែប៉ុណ្ណោះ។

ដូច្នេះ ចុងចម្លើយត្រូវទទួលបន្ទុកនូវប្រាក់ចំនួន៦០ម៉ឺនរៀលក្នុងមួយខែចំពោះកូនទាំងពីរ ដែលជាសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនទាំងពីរ រហូតដល់កូនទាំងពីរក្លាយជានីតិជន។

**ឃ. ការវិនិច្ឆ័យចំពោះការបែងចែកទ្រព្យសម្បត្តិ**

**ឃ.១. ការទទួលស្គាល់អង្គហេតុ**

ឃ.១.១. ដើមចោទ និងចុងចម្លើយមានទ្រព្យសម្បត្តិរួមដែលជាដីទំហំ២១១ម៉ែត្រការ៉េ ស្ថិតនៅភូមិអូរឬស្សីទី១ សង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១០០២១០០៣-០៤៤១ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤ និង ដីទំហំ៦៨៧ម៉ែត្រការ៉េ ស្ថិតនៅភូមិអូរឬស្សីទី២ សង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១០០២១០០៤-០៩៦៨ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ ដែលបានទិញរួមគ្នានៅក្នុងចំណងអាពាហ៍ពិពាហ៍។ ដីនេះជាប្រភេទដីលំនៅឋានដែលមិនទាន់មានការសាងសង់ណាមួយលើដីនោះឡើយ។

ឃ.១.២. ចំពោះដី និងផ្ទះ ទំហំ៦៨០ម៉ែត្រការ៉េ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១០០២១០០៣-០៤២៤ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ ស្ថិតនៅភូមិអូរឬស្សីទី១ សង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ ពីដើមឡើយជាដីកេរ្តិ៍ម្តាយរបស់ដើមចោទ ដែលបានឱ្យមកដើមចោទតាំងពីឆ្នាំ១៩៩០ ដីនោះមានទំហំ១២,៧ គុណនឹង៥០ម៉ែត្រ មានផ្ទះចាស់ ហើយបានរុះរើសង់ថ្មីជាមួយចុងចម្លើយ។ ចំណែកដីខាងក្រោយជាប់គ្នាគឺបងប្រុសរបស់ដើមចោទបានទិញ និងឱ្យមកដើមចោទដូចមានក្នុងកិច្ចសន្យាលក់ទិញ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៧។ នៅពេលមានការចុះបញ្ជីកម្មសិទ្ធិដើមចោទបានសម្រេចចិត្តយកចុះបញ្ជីទ្រព្យសម្បត្តិរួមជាមួយចុងចម្លើយ។ ចំណែកឯតម្លៃនៃការសាងសង់ផ្ទះរវាងដើមចោទ និងចុងចម្លើយនៅលើដីរបស់ដើមចោទមានតម្លៃប្រហែល៤០០០០$ ទៅ៥០០០០$ ។ ផ្ទះនេះ ដើមចោទ និងកូនៗកំពុងតែស្នាក់នៅបច្ចុប្បន្ននេះ។

ឃ.១.៣. ចំពោះដីចំការទំហំ១០០០០ (មួយម៉ឺន) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិចង្ក្រង ឃុំកសាង ស្រុកចិត្របុរី ខេត្តក្រចេះ គឺមិនមានដីនោះឡើយ ដោយសារដីនោះជាប្រភេទដីព្រៃ ដែលមិនដឹងទីតាំងច្បាស់លាស់ និងមិនមានឯកសារណាមួយបញ្ជាក់ពីការកាន់កាប់របស់ដើមចោទ និងចុងចម្លើយនោះទេ។



Scanned with CamScanner

ពាល់ដល់ផលប្រយោជន៍របស់ម្ចាស់បំណុលដែលជាតតិយជន។ ភាគីត្រូវទទួលខុសត្រូវដោយសាមគ្គីលើបំណុលរួម តាមការទាមទាររបស់ម្ចាស់បំណុលតែប៉ុណ្ណោះ។

**ច. អំពីបណ្តឹងតប**

តាមរយៈបណ្តឹងតប ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ របស់ចុងចម្លើយ ដែលមានខ្លឹមសារនៃសាលក្រមដែលទាមទារឱ្យតុលាការចេញ ដូចគ្នានឹងខ្លឹមសារនៃបណ្តឹងដើមដែលដើមចោទទាមទារតុលាការចេញ។ ការទាមទារក្នុងបណ្តឹងតបដូចគ្នានឹងការទាមទារក្នុងបណ្តឹងដើម ដោយគ្រាន់តែមានការបន្ថែមការទាមទារលើចំណុចនៃការទាមទារបែកចែកទ្រព្យរួមតែប៉ុណ្ណោះ ដែលការទាមទារនេះមិនចាំបាច់ធ្វើជាបណ្តឹងតបនោះទេ ដោយគ្រាន់តែធ្វើការអះអាងតប ដើម្បីបញ្ជាក់បន្ថែមលើចំណុចនៃទ្រព្យសម្បត្តិរួមដែលត្រូវធ្វើការបែងចែកតែប៉ុណ្ណោះ។ គប្បីតុលាការលើកបណ្តឹងចោលដោយមូលហេតុបណ្តឹងជាន់គ្នា តាមមាត្រា៨៣នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ឆ. អំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី**

តុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទចំពោះការទាមទារលែងលះ ដោយសារនៅក្នុងនីតិវិធីបណ្តឹងទាំងចុងចម្លើយក៏បានអះអាងថា ខ្លួនមិនមានអះអាងថាខ្លួនមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយដើមចោទដែរ ដូច្នេះហើយ មិនមែនមានន័យថាតុលាការបានទទួលស្គាល់អំពីមូលហេតុនៃការលែងលះដូចដើមចោទដែលបានអះអាងនោះទេ។ ហេតុនេះចំពោះបន្ទុកនៃប្រាក់ប្រដាប់ក្តី គប្បីឱ្យភាគីដើមចោទដែលឈ្នះក្តីទទួលបន្ទុកមួយដែរ (មាត្រា៦៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដោយទទួលបន្ទុកម្នាក់ៗចំនួន១ភាគ២។

**៣.សេចក្តីសម្រេចបញ្ចប់**

**១.** ឱ្យដើមចោទឈ្មោះ [redacted] ស៊ីណាត លែងលះពីចុងចម្លើយឈ្មោះ [redacted] អេងប៊ាង។

**២.** កំណត់យកដើមចោទឈ្មោះ [redacted] ស៊ីណាត ជាអ្នកមានអំណាចមេបាលើកូនប្រុសពីរនាក់ ឈ្មោះ [redacted] សេងហួរ ភេទប្រុស កើតថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៤ និងឈ្មោះ [redacted] សេងហុង ភេទប្រុស កើតថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦។

**៣.** បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] អេងប៊ាង បង់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រង និងថែរក្សាកូនចំនួន៦០០,០០០ (ហុកសិបម៉ឺន) រៀល ក្នុង០១ខែ ឱ្យទៅដើមចោទឈ្មោះ [redacted] ស៊ីណាត រហូតកូនដល់នីតិភាព។

**៤.** ប្រគល់ដី និងផ្ទះ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១០០២១០០៣-០៤២៤ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ ដែលមានទីតាំងស្ថិតនៅភូមិអូរឫស្សីទី១ សង្កាត់អូរឫស្សី ក្រុង ក្រចេះ ខេត្តក្រចេះ ទៅឱ្យដើមចោទឈ្មោះ [redacted] ស៊ីណាត ដោយឱ្យចុងចម្លើយឈ្មោះ [redacted] អេងប៊ាង ធ្វើនីតិវិធីចុះបញ្ជីផ្ទេរចំណែកកម្មសិទ្ធិពាក់កណ្តាលរបស់ខ្លួនមកឱ្យដើមចោទឈ្មោះ [redacted] ស៊ីណាត និងបង្គាប់ឱ្យដើមចោទឈ្មោះ [redacted] ស៊ីណាត បង់ប្រាក់ចំនួន២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ឱ្យទៅចុងចម្លើយឈ្មោះ [redacted] អេងប៊ាង ជាថ្នូរនៃចំណែកពាក់កណ្តាលដែលមានលើផ្ទះ។



Scanned with CamScanner

**៥. ការបែងចែកទ្រព្យសម្បត្តិរួម៖**

៥.១. ប្រគល់ដីទំហំ ២១១ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១០០២១ ០០៣-០៤៤១ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤ ដែលមានទីតាំងស្ថិតនៅភូមិអូរឬស្សីទី១ សង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ ទៅឱ្យដើមចោទឈ្មោះ [redacted] ស៊ីណាត ដោយឱ្យចុងចម្លើយឈ្មោះ [redacted] អេងហ៊ាង ធ្វើនីតិវិធីចុះបញ្ជីផ្ទេរចំណែកកម្មសិទ្ធិពាក់កណ្ដាលរបស់ខ្លួនមកឱ្យដើមចោទឈ្មោះ [redacted] ស៊ីណាត។

៥.២. ប្រគល់ដីទំហំ ៦៨៧ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១០០២១ ០០៣-០៩៦៨ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ ដែលមានទីតាំងស្ថិតនៅភូមិអូរឬស្សីទី២ សង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ ទៅឱ្យចុងចម្លើយឈ្មោះ [redacted] អេងហ៊ាង ដោយឱ្យដើមចោទឈ្មោះ [redacted] ស៊ីណាត ធ្វើនីតិវិធីចុះបញ្ជីផ្ទេរចំណែកកម្មសិទ្ធិពាក់កណ្ដាលរបស់ខ្លួនមកឱ្យចុងចម្លើយឈ្មោះ [redacted] អេងហ៊ាង។

៥.៣. ការទាមទារលើសពីនេះច្រានចោល។

៦. លើកចោលបណ្ដឹងតប ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ របស់ចុងចម្លើយ ។

៧. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ១ភាគ២ និងចុងចម្លើយ១ភាគ២។

សាលក្រមនេះបានប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ និងចុងចម្លើយ ។

ថ្ងៃអង្គារ ១៥កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ក្រចេះ, ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០

**ចៅក្រម**

**ហត្ថលេខា និងត្រា៖** [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១៥កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ក្រចេះ, ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

ថ្ងៃអង្គារ ១៥កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ក្រចេះ, ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០

**ចៅក្រម**

[redacted]



Scanned with CamScanner